ថ្ងៃទី 23 មីនា ឆ្នាំ 2012

# ការិយាល័យនៃ អ្នករដ្ឋបាលបណ្តឹងទាមទារសំណងដែលតែងតាំងដោយតុលាការ កម្មវិធីបណ្តឹងទាមទារសំណងដែលត្រួតពិនិត្យដោយតុលាការស្តីពីករណីហៀរកំពប់ប្រេងរបស់ក្រុមហ៊ុន ប៊ីភី

## សេក្តីប្រកាសព័ត៌មាន

អ្នករដ្ឋបាលបណ្តឹងទាមទារសំណងដែលត្រួតពិនិត្យដំណើរការអន្តរកាលដែលបង្កើតដោយ ចៅក្រម Carl Barbier នៃតុលាការខណ្ឌភាគខាងកើតរបស់រដ្ឋល្វីស្សអេណា សហរដ្ឋអាមេរិច ក្នុងដីកាដែលបានធ្វើវិសោធនកម្មលើកទីមួយដើម្បីបង្កើតដំណើរការអន្តរកាល (ឬហៅកាត់ថា "ដីកា") បានប្រកាសនៅថ្ងៃនេះថា ដំណើរការអន្តរកាលនេះ កំពុងសម្រេចគោលដៅរបស់ខ្លួនក្នុង ការបន្តផ្តល់នូវការពិនិត្យសារឡើងវិញ និងការបង់ប្រាក់ដល់អ្នកប្តឹងទាមទារសំណង ដែលបានដាក់បណ្តឹងជូន Gulf Coast Claims Facility (ឬហៅកាត់ថា «GCCF») នៅពេលដែលដំណើរការអន្តរកាលនេះបានមកជំនួស កាលពីថ្ងៃទី 8 មីនា ឆ្នាំ2012។

តុលាការបានចេញដីការបស់ខ្លួន ដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រាងជាគោលការណ៍ រវាងក្រុមហ៊ុន ប៊ីភី Exploration and Production, Inc. និង ប៊ីភី America Production Company ជាមួយនឹងក្រុមប្រឹក្សាបណ្តឹងជាថ្នាក់បណ្តោះអាសន្ន ដើម្បីដោះស្រាយរឿងក្តីជាច្រើន ដែលកើតចេញពីការហៀរកំពប់ប្រេងក្នុងដែនសមុទ្រទឹកជ្រៅ។ ដំណោះស្រាយមិនត្រូវបានគេសម្រេចបញ្ចប់នៅឡើយ ហើយចុងក្រោយគឺអាស្រ័យលើការអនុម័តរបស់តុលាការ។

ដីកានេះបានតែងតាំងលោក Patrick Juneau នៅ Lafayette រដ្ឋល្វីស្សអេណា (Louisiana) ជាអ្នករដ្ឋបាលបណ្តឹងទាមទារសំណង ដើម្បីត្រួតពិនិត្យដំណើរការអន្តរកាល ជាមួយនឹង Lynn C. Greer នៃក្រុមហ៊ុន BrownGreer, PLC នៅ Richmond រដ្ឋ Virginia ជាអ្នកសម្របសម្រួលអន្តរកាល។ តុលាការបានបង្កើតដំណើរការអន្តរកាលនេះឡើងជាស្ពានរវាង GCCF និងមជ្ឈមណ្ឌលបណ្តឹងសំណងថ្មីមួយដែល នឹងជំនួស GCCF។ មជ្ឈមណ្ឌលទទួលពាក្យបណ្តឹងថ្មីនេះនឹងទទួល ហើយ វាយតំលៃពាក្យបណ្តឹងទាមទារសំណង និង ប្រសិនបើអាចធ្វើទៅបាន បង់ប្រាក់ទូទាត់ពាក្យបណ្តឹងទាមទារសំណងដែលបានចែងនៅក្នុងដំណោះស្រាយដែលគេបានរំពឹងទុក។
អំឡុងពេលដែលមជ្ឈមណ្ឌលបណ្តឹងទាមទារសំណងថ្មីកំពុងត្រូវបង្កើតឡើង ដីកានេះកំណត់ថដំណើរការអន្តរកាលបន្តដោះស្រាយបណ្តឹងទាមទារសំណង ក្រោមវិធានបច្ចុប្បន្នរបស់ GCCF ដោយមានការផ្លាស់ប្តូរមួយចំនួនទៅតាមការកំណត់របស់តុលាការ។

ចាប់តាំងពីបានទទួលខុសត្រូវចំពោះបណ្តឹងទាមទារសំណងដែលបានដាក់ជូន GCCFមក ដំណើរការអន្តរកាលបានបន្តដោះស្រាយនិងទូទាត់បង់សំណង។ តាមប្រសាសន៍របស់ លោក Juneau «ចាប់តាំងពីថ្ងៃទី 8 មីនា 2012 មក ពុំដែលមានថ្ងៃធ្វើការណាមួយដែលពុំមានការទូទាត់បង់សំណងជូនដល់អ្នកប្តឹងទាមទារឡើយ។» ចាប់តាំងពីថ្ងៃទី 8 មីនា ឆ្នាំ 2012 រហូតដល់ថ្ងៃទី 21 មីនា 2012 ដំណើរការអន្តរកាលបានចេញការទូទាត់បង់សំណងជូនដល់អ្នកប្តឹងទាមទារចំនួន 1,096 នាក់ ក្នុងទឹកប្រាក់សរុបចំនួន 26,993,189.98 ដុល្លារ។ ក្នុងចំណោមនេះ 619 នាក់ជាអ្នកប្តឹងដែលពុំធ្លាប់បានទទួលយកសំណើផ្តល់ជូនប្រាក់សំណង និងពុំបានដាក់ពាក្យលះបង់សិទ្ធិប្តឹងទាមទារសំណងមុនម៉ោង 11:59 នាទីយប់ ថ្ងៃទី

26 កុម្ភៈ ឆ្នាំ 2012។ ដីកានេះបានកំណត់ឲដំណើរការអន្តរកាលបង់ប្រាក់សំណងជូនអ្នកប្តឹងទាមទារបែបនេះ ចំនួន 60% នៃសំណើផ្តល់ជូនប្រាក់សំណងចុងក្រោយរបស់ពួកគាត់ ដោយពុំតម្រូវឲអ្នកប្តឹងនោះ ចុះហត្ថលេខាលះបង់សិទ្ធិប្តឹងទាមទារទេ។ អ្នកប្តឹងទាមទារចំនួន 619 រូបនោះដែលបានទទួលប្រាក់ 60% នៃសំណើផ្តល់ជូនប្រាក់សំណងចុងក្រោយរបស់ពួកគាត់ បានទទួលប្រាក់សរុបចំនួន 19,623,125.10 ដុល្លារ។

អ្នកប្តឹងទាមទារទាំងនេះដែលបានទទួលប្រាក់ 60% នៅពេលឥឡូវនេះ នឹងមិនបាត់សិទ្ធិទទួលបានប្រាក់សេសសល់ 40% ទៀតនៃសំណើផ្តល់ជូនចុងក្រោយរបស់ពួកគាត់ឡើយ។ ពួកគាត់ប្រហែលនឹងអាចទទួលបានច្រើនជាងនេះទៅទៀតផង ប្រសិនបើពួកគាត់ជាសមាជិកនៃបណ្តឹងទាមទារជាថ្នាក់ ហើយដែលទទួលបាននូវសំណើផ្តល់ជូនមួយ ដែលច្រើនជាង 40% ពីកម្មវិធីដោះស្រាយបណ្តឹងដែលត្រួតពិនិត្យដោយតុលាការ។ ជាការពិតណាស់ ដីការបស់តុលាការនេះអនុញ្ញាតឲអ្នកប្តឹងទាមទារ ទាំងនោះ ទទួលបានច្រើនជាង 40% នៃប្រាក់ដែលសេសសល់ពីការផ្តល់ជូនរបស់ GCCF ឬ ការផ្តល់ជូនពីកម្មវិធីដោះស្រាយបណ្តឹងដែល ត្រួតពិនិត្យដោយតុលាការ ដើម្បីជាការដោះដូរ ជាមួយនឹងការចុះហត្ថលេខាលះបង់សិទ្ធិប្តឹងទាមទារសំណង។ ប្រសិនបើអ្នកប្តឹងម្នាក់មិនស្ថិត នៅក្នុងដំណើរការដោះស្រាយបណ្តឹងនេះទេ ឬជ្រើសរើសដកខ្លួនចេញដំណើរការនោះ អ្នកប្តឹងរូបនោះអាចទទួលបាន 40% នៅពេលនោះ បន្ទាប់ពីបានចុះហត្ថលេខាលះបង់សិទ្ធិប្តឹង។

បន្ថែមទៅលើការបន្តទូទាត់បង់សំណង ដំណើរការអន្តរកាលបានបន្តពិនិត្យសារឡើងវិញនូវពាក្យបណ្តឹងទាមទារសំណងក្រោមវិធាននិងវិធីសាស្ត្ររបស់ GCCF ហើយនិងបន្តចេញនូវសេចក្តីសម្រេចទៅលើបណ្តឹងទាមទារសំណង។ ដំណើរការអន្តរកាល បានផ្ញើលិខិតសំណើផ្តល់ជូនសំណង ឬ សេចក្តីសម្រេចចំនួន 897 ច្បាប់ ជូនដល់អ្នកប្តឹងទាមទារ លិខិតស្នើសុំឯកសារបន្ថែមចំនួន 1,918 ច្បាប់ និងលិខិតបដិសេធបណ្តឹងទាមទារដែលពុំមានសិទ្ធិទទួលបានផលប្រយោជន៍ទាំងនេះ ចំនួន 2,506 ច្បាប់។

លោក Juneau បានមានប្រសាសន៍ថា «ការប្រាស្រ័យទាក់ទងជាមួយ នឹងអ្នកប្តឹងទាមទារ កាន់តែមានសារៈសំខាន់ជាងពេលមុនទៅទៀត ហើយយើងចង់ធានាអះអាងប្រាប់អ្នកប្តឹងទាមទារសំណង ថា ទ្វារមិនដែលបិទឡើយចំពោះពួកគាត់»។ ក្នុងរយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីដីការបស់តុលាការ ដំណើរការអន្តរកាលបានផ្ញើលិខិតជូនដល់អ្នកប្តឹងទាមទារចំនួន 20,000 រូប ដែលមានសិទ្ធិទទួលបានជម្រើសទូទាត់សងសំណងឆាប់រហ័ស និងដែលមានពេលរហូតដល់ថ្ងៃទី 7 ឧសភា ឆ្នាំ 2012 ដើម្បីជ្រើសរើសយកជម្រើសនោះ។ ដំណើរការនេះក៏បានផ្ញើលិខិតជាង 1,700 ច្បាប់ ជូនដល់អ្នកប្តឹងទាមទារដែលកំពុងរង់ចាំសំណើផ្តល់ជូនពី GCCF និងលិខិតជាង 17,000ច្បាប់ ជូនដល់អ្នកប្តឹងទាមទារដែលបានដាក់ពាក្យបណ្តឹងជូន GCCF។ លិខិតទាំងនេះបានផ្តល់ជូនដល់អ្នកប្តឹង នូវព័ត៌មានស្តីពីដីការបស់តុលាការ និងជម្រើសទៅមុខទៀតរបស់ពួកគាត់។

ក្នុងរយៈពេលប៉ុន្មានម៉ោងក្រោយពីចេញដីកាតុលាការនេះ វិបសាយរបស់ GCCF ត្រូវបានផ្លាស់ប្តូរ ដើម្បីប្រាប់ដំណឹងជូនដល់អ្នកប្តឹងទាមទារពីដីការតុលាការនេះ មជ្ឈមណ្ឌលឆ្លើយឆ្លងទូរស័ព្ទបានបន្ថែមម៉ោងដើម្បីជួយសម្រួលដល់ការហៅទូរស័ព្ទដែលមានចំនួនកើនឡើង ហើយអ្នកប្រតិបត្តិការក្នុងមជ្ឈមណ្ឌលឆ្លើយឆ្លងទូរស័ព្ទនេះបានផ្តល់ព័ត៌មាន ជូនដល់អ្នកទូរស័ព្ទមកសួរអំពីដំណើរការអន្តរកាលនេះ។ លោក Juneau បានមានប្រសាសន៍ថា «យើងបានទទួលការហៅទូរស័ព្ទចូលនិងអ៊ីម៉េលសួរសំណួររាប់ពាន់ ហើយយើងនៅទីនោះដើម្បីផ្តល់ព័ត៌មានទូទៅ ឬ ព័ត៌មានជាក់លាក់ពីបណ្តឹងទាមទារសំណងរបស់ពួកគាត់»។

ចាប់តាំងពីថ្ងៃចេញដីកាតុលាការមក ពាក្យបណ្តឹងទាមទារថ្មីជិត 5,000 បណ្តឹងត្រូវបានដាក់មកក្នុងដំណើរការអន្តរកាលនេះ ដោយរាប់បញ្ចូលទាំងពាក្យបណ្តឹងចំនួន 1,700 ពីអ្នកប្តឹងទាមទារ ដែលមិនធ្លាប់ដាក់ពាក្យប្តឹងពីមុនមកផងដែរ។ លោក Juneau បានមានប្រសាសន៍ថា "យើងចង់ឲប្រជាពលរដ្ឋនៅតំបន់ឈូងសមុទ្រនេះដឹងថា ពួកគាត់នៅតែអាចដាក់ពាក្យបណ្តឹង។ នៅពេលដែលកម្មវិធីថ្មីបើកឡើង រាល់បណ្តឹងដែលមិនទាន់បានដោះស្រាយសម្រេច នឹងត្រូវផ្ទេរមកកម្មវិធីថ្មីនេះ ដូច្នេះមិនចាំបាច់ត្រូវរង់ចាំឡើយ"។